ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពត

សំណុំរឿងរដ្ឋប្បវេណីលេខ ១៨០
ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០

**សាលក្រមលេខៈ ៨០ - ក -**
ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពត

- បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅសាលសវនាការ។
- កាលបរិច្ឆេទបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣។
- កាលបរិច្ឆេទប្រកាសសាលក្រម នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣ វេលារសៀល។

### ចៅក្រមជំនុំជម្រះ

ឯកឧត្តម [redacted] ជាប្រធានសាលាដំបូងខេត្តកំពត

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពត

**១. គូភាគី៖**

**ដើមចោទ៖**

ឈ្មោះ [redacted] ស៊ីវហុង ភេទស្រី អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ [redacted] មានលោកមេធាវី [redacted] និងលោកស្រីមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិ។

**សហចុងចម្លើយ៖**

១. ឈ្មោះ [redacted] ស៊ីគួរ ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ [redacted] ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៤ [redacted]

២. ក្រុមហ៊ុន [redacted] ដែលមានវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មលេខ ០០០៣៥៦៤៤ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ ដែលមានអាសយ [redacted] និងមានឈ្មោះ [redacted] ហែន ភេទប្រុស ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ [redacted] ជាប្រធានក្រុមប្រឹក្សាក្រុមហ៊ុន, ឈ្មោះ [redacted] ណៃហ៊ុយ ភេទស្រី អាយុ២៤ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ [redacted] ចុះថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៣ ជាតំណាងប្រតិបត្តិកររបស់ក្រុមហ៊ុន, ឈ្មោះ [redacted] ព្រើន្សយ៉ា ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ [redacted] ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៨ ជា



Scanned with CamScanner

តំណាងប្រតិបត្តិកររបស់ក្រុមហ៊ុនឈ្មោះ [redacted] ចរិយា ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ [redacted] ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៨ ជាអ្នកតំណាងប្រតិបត្តិកររបស់ក្រុមហ៊ុន។

៣. ក្រុមហ៊ុន [redacted] ដែលមានវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម លេខ ០០០១៥៣៩៨ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៦ ដែលមានអាសយដ្ឋានស្ថិតនៅ [redacted] និងឈ្មោះ [redacted] តារា មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ [redacted] ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ជាប្រធានក្រុមប្រឹក្សាភិបាល និងឈ្មោះ [redacted] សញ្ជាតិខ្មែរ [redacted] ជាអភិបាលជាអ្នកតំណាងប្រតិបត្តិករក្រុមហ៊ុន។

មានលោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិ។

## ២. ខ្លឹមសារនៃសាលក្រមដែលទាមទារ៖

### ២.១. ខ្លឹមសារដែលដើមចោទទាមទារឱ្យតុលាការចេញសាលក្រម៖

១. បង្គាប់ឱ្យសហចុងចម្លើយទទួលខុសត្រូវរួមគ្នា និង/ឬដោយឡែកពីគ្នាសងតាមតម្លៃនៃការទិញលក់ដីចំការយោងតាមកិច្ចសន្យាទិញលក់ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ដល់ឈ្មោះ [redacted] ស៊ីវហុង ចំនួន ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក។

២. បង្គាប់ឱ្យសហចុងចម្លើយទទួលខុសត្រូវរួមគ្នា និង/ឬដោយឡែកពីគ្នា សំណងជំងឺចិត្ត ការខាតបង់ពេលវេលា និងសេវាកម្មច្បាប់ដល់ឈ្មោះ [redacted] ស៊ីវហុង ចំនួន ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក។

៣. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ។

## ៣. អង្គហេតុ និងចំណុចវិវាទ៖

### ៣.១. ការពន្យល់ត្រួសៗអំពីរឿងក្ដី៖

កាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៩ ក្រុមហ៊ុន [redacted] ដែលមានវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្មលេខ ០០០៣៥៦៤៤ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៨ ដែលមានអាសយដ្ឋានស្ថិតនៅអាគារ [redacted] ដែលមានឈ្មោះ [redacted] ព្រីន្សយ៉ា, ឈ្មោះ [redacted] ចរិយា និងឈ្មោះ [redacted] ស៊ីគួរ ទាំង៣នាក់ខាងលើបានរួមគ្នាធ្វើជាអ្នកតំណាងប្រតិបត្តិករឱ្យភាគីអ្នកទិញ ក្នុងការចុះកិច្ចសន្យាទិញលក់ពីក្រុមហ៊ុន [redacted] ដែលមានវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មលេខ ០០០១៥៣៩៨ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៦ ដែលមានអាសយដ្ឋានស្ថិតនៅ [redacted] និងមានឈ្មោះ [redacted] តារា ជាប្រធានក្រុមប្រឹក្សាភិបាល និងមានឈ្មោះ [redacted] សឹងបេ សញ្ជាតិខ្មែរ ជាអភិបាល និងជាអ្នកតំណាងប្រតិបត្តិកររបស់អ្នកលក់។ កម្មវត្ថុនៃការទិញលក់ និងទីតាំងដីស្ថិតនៅភូមិជ័យសេនា និងភូមិតេជោជ្រៃបាក់ ឃុំតាកែន និងឃុំតេជោអភិវឌ្ឍន៍ ស្រុកឈូក ខេត្តកំពត លើក្រឡាផ្ទៃសរុបចំនួន ១,៣០០ ហិកតា (ក្នុងនោះដីមានប័ណ្ណកម្មសិទ្ធិទំហំ ៨៣៦ ហិកតា និងដីពុំមានប័ណ្ណកម្មសិទ្ធិទំហំ ៤៦៤ ហិកតា)។ ក្រោយពីបានប្រគល់ប្រាក់ទូទាត់ដៃ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៩ និងបន្តបន្ទាប់មកទៀតបានធ្វើការបង់ប្រាក់ជាដំណាក់កាលរហូតដល់ថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៩។ ក្នុងអំឡុងពេលនៃការទិញលក់រវាងភាគីអ្នកលក់ និងភាគីអ្នកទិញនេះ, សហចុងចម្លើយដែលមានឈ្មោះ [redacted] ចរិយា និងឈ្មោះ [redacted] ស៊ីគួរ បានធានាអះអាងថាក្រុមហ៊ុនរបស់ខ្លួនខាងលើ បានទទួលសិទ្ធិបន្តក្នុងការចាត់ចែងដីចំការនៃកម្មវត្ថុទិញលក់នេះ ដើម្បីអភិវឌ្ឍន៍ពុះឡូតិ៍លក់បន្តទៅឱ្យអតិថិជននៅលើទីផ្សារអចលនទ្រព្យ

បានត្រឹមត្រូវតាមផ្លូវច្បាប់។ អ្នកតំណាងសហចុងចម្លើយទាំងពីរនាក់ខាងលើ គឺគ្រាន់តែបានធានាអះអាងផ្ទាល់មាត់តែប៉ុណ្ណោះទេ ដោយមិនមានការផ្តល់ឯកសារថតចម្លងណាមួយជូនអតិថិជនដែលទិញបន្តនោះឡើយ។

នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ឈ្មោះ [redacted] ស៊ីហុង បានចុះកិច្ចសន្យាទិញលក់ដីចំការនៃកម្មវត្ថុដីក្សាការពារនេះពីសហចុងចម្លើយចំនួនមួយហិកតា ក្នុងតម្លៃចំនួន ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក និងបានទូទាត់គ្រប់ចំនួនជូនសហចុងចម្លើយរួចហើយ។ ភាគីរបស់សហចុងចម្លើយបានធានាអះអាងថា ក្រុមហ៊ុនរបស់ខ្លួនខាងលើត្រូវពុះឡូត៍ដី និងចេញប័ណ្ណកម្មសិទ្ធិ និងដាំដំណាំធុរេនចំនួន១២០ដើម ជូនដើមចោទ ក្នុងអំឡុងពេល៣ខែ គិតចាប់ពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩។ រហូតមកដល់ពេលនេះ ភាគីសហចុងចម្លើយបានទទួលប្រាក់គ្រប់ចំនួនរួចហើយក៏ប៉ុន្តែ មិនបានបំពេញកាតព្វកិច្ចតាមកិច្ចសន្យារបស់ខ្លួនឡើយ។ ដើមចោទបានទៅពិនិត្យមើលទីតាំងដីក្នុងកំឡុងពេលខែមិថុនា ឆ្នាំ២០១៩ ដោយឃើញផ្ទាល់នឹងភ្នែកថាទីតាំងដីនោះត្រូវបានការពារដោយកម្លាំងសន្តិសុខដោយមិនឱ្យដើមចោទចូលទៅមើលដីទេ ហើយទីតាំងដីមិនមានការដាំដុះដំណាំធុរេនចំនួន១២០ដើមឡើយ សំខាន់ជាងនេះទៅទៀត មិនត្រឹមតែមិនផ្ទេរកម្មសិទ្ធិ និងចេញប័ណ្ណកម្មសិទ្ធិឱ្យដើមចោទទេ ថែមទាំងបិទទ្វារក្រុមហ៊ុនរបស់ខ្លួននៅកំពត និងទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញដោយមិនមានការជូនដំណឹង និងខ្វះការទទួលខុសត្រូវតាមផ្លូវច្បាប់ទាំងស្រុង។ កន្លងមកដើមចោទបានធ្វើការទំនាក់ទំនងទៅសហចុងចម្លើយ ដែលមានឈ្មោះ [redacted] ហែម, ឈ្មោះ [redacted] ណៃហ៊ុយ, ឈ្មោះ [redacted] គ្រីស្សយ៉ា, ឈ្មោះ [redacted] ចរិយា និងឈ្មោះ [redacted] ស៊ីគួរ តាមការជួបដោយផ្ទាល់ និងតាមទូរស័ព្ទ ដើម្បីអនុវត្តនីតិវិធីចុះបញ្ជីផ្ទេរកម្មសិទ្ធិ និង/ឬទាមទារសំណង ទាំងប្រាក់ដើមនៃការទិញលក់ និងសំណងជំងឺចិត្ត សហចុងចម្លើយបានគេចវេស បិទទ្វារក្រុមហ៊ុនរត់គេចខ្លួនរហូតដល់បច្ចុប្បន្ននេះ មិនអាចធ្វើការទំនាក់ទំនងបានឡើយ។

ដោយហេតុថា ក្រុមហ៊ុន [redacted] ជាសហកូនបំណុលនៅក្នុងដីកាសម្រេចក្សាការពារលេខ ៥៣ "ឃ" ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ នៃសាលាដំបូងខេត្តកំពត ទើបដើមចោទអះអាងថាមានមូលហេតុទំនាក់ទំនងគតិយុត្តត្រឹមត្រូវតាមច្បាប់ ដើម្បីឱ្យដើមចោទឈ្មោះ [redacted] ស៊ីហុង បានចូលរួមនីតិវិធីតុលាការក្នុងនាមជាបណ្តឹងតតិយជនទាំងនៅក្នុងសំណុំរឿងក្សាការពារលេខ ៤៣ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២០ នៃសាលាដំបូងខេត្តកំពត និងនៅអង្គសេចក្តី។

### ៣.២. ចំណុចវិវាទ៖

១. តើដើមចោទបានចុះកិច្ចសន្យាទិញលក់ដីចំការជាមួយសហចុងចម្លើយមួយណា?

២. តើក្រុមហ៊ុន [redacted] ជាភាគីដែលត្រូវអនុវត្តកាតព្វកិច្ចជាមួយដើមចោទដែរឬទេ?

៣. តើដើមចោទមានអត្ថិភាពក្នុងការទាមទារឱ្យសហចុងចម្លើយមួយណាអនុវត្តកាតព្វកិច្ចសងប្រាក់ថ្លៃទិញលក់ដី

### ៣.៣. ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទ៖

- លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្ញុំមិនមានអ្វីជំទាស់ចំពោះនីតិវិធីថ្ងៃនេះនោះទេ សុំបន្តនីតិវិធីនៅថ្ងៃនេះ។ ខ្ញុំបាទសុំរក្សាលើការទាមទារ និងអង្គហេតុដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង និងពាក្យសុំកែតម្រូវពាក្យបណ្តឹងរបស់ខ្ញុំបាទ និងកំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលកន្លងមក។ និងស្នើសុំឱ្យតុលាការពិនិត្យលើភស្តុតាងដែលសហចុងចម្លើយបានចុះកិច្ចសន្យា និងទទួលប្រាក់ពីកូនក្តីខ្ញុំទាំងអស់ តែចុងក្រោយមិនបានទាំងដី និងអស់ទាំងលុយថែមទៀត
- លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយក្រុមហ៊ុន [redacted] បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្ញុំសូមបញ្ជាក់ថា ឈ្មោះ [redacted] ស៊ីគួរ និងឈ្មោះ [redacted] ចរិយា បានមកទិញដីរបស់ក្រុមហ៊ុន [redacted] តែមិនបានប្រគល់ប្រាក់ឱ្យក្រុមហ៊ុននោះទេ និងបានដាច់ប្រាក់ហើយ។ ចំពោះឈ្មោះ [redacted] ស៊ីគួរ និងឈ្មោះ [redacted] ចរិយា យកដីរបស់ក្រុមហ៊ុនខ្ញុំបាទដែលមិនទាន់បានទិញលក់ ត្រឹមតែប្រាក់មួយចំនួននោះទៅធ្វើអីនោះខ្ញុំបាទមិនដឹងទេ។ សំណូមពរ ឱ្យតុលាការច្រានចោលការទាមទាររបស់ដើមចោទដែលទាមទារលើក្រុមហ៊ុនកូនក្តីខ្ញុំបាទ។

- លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្ញុំបាទសុំច្រានចោលការថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិរបស់ក្រុមហ៊ុន [redacted] ដោយសារតែកូនក្តីខ្ញុំបានទិញដីពីសហចុងចម្លើយឈ្មោះ [redacted] ស៊ីគួរ និងឈ្មោះ [redacted] ម្ចាស់ដី រួចហើយ និងបានប្រគល់ប្រាក់មួយចំនួនរួចហើយ។ និងដោយសារតែក្រុមហ៊ុន [redacted] បានអនុញ្ញាតឱ្យក្រុមហ៊ុន [redacted] ម្ចាស់ដី និងឈ្មោះ [redacted] ស៊ីគួរ យកដីនេះទៅពុះឡូតិ៍លក់ ទើបធ្វើឱ្យកូនក្តីខ្ញុំ និងអ្នកផ្សេងទៀតដែលរងគ្រោះទៅទិញដីតែមិនបានដីនិងអស់លុយថែមទៀតផង។ បើសិនជាគ្មានការអនុញ្ញាតពីក្រុមហ៊ុន [redacted] ដែលជាម្ចាស់ដីដើមទេ ប្រាកដជាមានការជំទាស់ពីក្រុមហ៊ុន [redacted] នៅពេលដែលក្រុមហ៊ុន [redacted] ម្ចាស់ដី និងឈ្មោះ [redacted] ស៊ីគួរ បានពុះឡូតិ៍លក់ និងផ្សព្វផ្សាយពេញនឹង។ នៅមុនពេលទិញដីគឺខ្ញុំ និងកូនក្តីបានទៅមើលនៅទីតាំងដីជាក់ស្តែង និងឃើញមានការអភិវឌ្ឍន៍លើដីប្រាកដមែន ទើបឈានដល់ការចុះកិច្ចសន្យាទិញលក់ដី និងប្រគល់ប្រាក់បង្គ្រប់តែម្តង។

- លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយក្រុមហ៊ុន [redacted] បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្ញុំសូមបញ្ជាក់ថា មុននឹងដើមចោទទិញដី គប្បីពិនិត្យមើលប្លង់កម្មសិទ្ធិជាអ្នកណា ហើយនៅពេលដែលដើមចោទចុះកិច្ចសន្យាជាមួយម្ចាស់ដីដែលជាកូនក្តីរបស់ខ្ញុំបាទ ឬចុះជាមួយអ្នកណាសិន។ កូនក្តីខ្ញុំបានចុះកិច្ចសន្យាជាមួយនឹងក្រុមហ៊ុន [redacted] ម្ចាស់ដី តែកិច្ចសន្យានេះបានបញ្ចប់ហើយ ដោយសារតែគាត់មិនបានទូទាត់ប្រាក់មកកូនក្តីខ្ញុំ ដោយក្រុមហ៊ុន [redacted] ម្ចាស់ដី ទើបតែបានបង់ប្រាក់ឱ្យកូនក្តីខ្ញុំតែមួយលើកប៉ុណ្ណោះ។

- លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្ញុំបាទស្នើសុំឱ្យតុលាការសម្រេចតាមការទាមទាររបស់កូនក្តីខ្ញុំ។

- លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយក្រុមហ៊ុន [redacted] បានធ្វើសេចក្តីថ្លែងការណ៍ថា៖ យើងខ្ញុំសូមឱ្យតុលាការច្រានចោលការទាមទាររបស់ដើមចោទចំពោះកូនក្តីខ្ញុំ ដោយសារកូនក្តីខ្ញុំមិនមានទំនាក់ទំនងគតិយុត្តជាមួយនឹងដើមចោទនោះទេ។

## ៤. សំអាងហេតុ:

ឆ្លងតាមលទ្ធផលសាកសួរ និងពិនិត្យកស្តុតាងនៅនីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖

### ៤.១. អំពីការវិនិច្ឆ័យការទាមទាររបស់ដើមចោទ៖

១. ដើមចោទបានបានដាក់ពាក្យបណ្តឹងតវ៉ាតតិយជន ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ និងចុះជាសំណុំរឿងបណ្តឹងតវ៉ាតតិយជនលេខ ១៨០ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងខេត្តកំពត ដែលមានខ្លឹមសារនៃការទាមទារដូចខាងក្រោម៖

*ក. ទទួលស្គាល់បណ្តឹងតវ៉ាតតិយជនដែលមាននាងខ្ញុំជាអ្នករងគ្រោះ និងជាម្ចាស់បំណុលនៅក្នុងការអនុវត្តដីកាសម្រេចរក្សាការពារលេខ ៥៣ "ឃ" ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ នៃសាលាដំបូងខេត្តកំពត។*

*ខ. សុំរក្សាទុកនូវសេចក្តីសម្រេចខ្លឹមសារទាំងមូលរបស់ដីកាសម្រេចរក្សាការពារលេខ ៥៣ "ឃ" ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ នៃសាលាដំបូងខេត្តកំពត។*

*គ. បង្គាប់សហចុងចម្លើយទទួលខុសត្រូវរួមគ្នា និង/ឬដោយឡែកពីគ្នាសងការខូចខាតកេរ្តិ៍ឈ្មោះដល់ឈ្មោះ [redacted] ស៊ីវហុង ចំនួន USD ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក។*

*ឃ. បង្គាប់សហចុងចម្លើយទទួលខុសត្រូវរួមគ្នា និង/ឬដោយឡែកពីគ្នា សងតាមតម្លៃនៃការទិញ-លក់ដីចំការ យោងតាមកិច្ចសន្យាទិញ-លក់ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ដល់ឈ្មោះ [redacted] ស៊ីវហុង ចំនួន USD ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក។*

*ង. បង្គាប់សហចុងចម្លើយទទួលខុសត្រូវរួមគ្នា និង/ឬដោយឡែកពីគ្នា សំណងជំងឺចិត្ត ការខាតបង់ពេលវេលា និងសេវាកម្មច្បាប់ដល់ឈ្មោះ [redacted] ស៊ីវហុង ចំនួន USD ៣០,០០០ (បីម៉ឺន)*

*ដុល្លារអាមេរិក។*

*ច.* *សុំឱ្យមានការអនុវត្តបណ្តោះអាសន្នលើចំណុច ១ និងទី២ ខាងលើ។*

*ឆ.* *ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។*

ចៅក្រម បានណែនាំដោយផ្ទាល់មាត់ឱ្យមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទកែតម្រូវពាក្យបណ្តឹងលើខ្លឹមសារនៃការទាមទារ ហើយដើមចោទបានកែតម្រូវតាមពាក្យសុំកែតម្រូវពាក្យបណ្តឹង ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ ដែលមានខ្លឹមសារនៃការទាមទារដូចខាងក្រោម៖

*ក.* *បង្គាប់ឱ្យសហចុងចម្លើយទទួលខុសត្រូវរួមគ្នា និង/ឬដោយឡែកពីគ្នាសងតាមតម្លៃនៃការទិញលក់ដីចំការ យោងតាមកិច្ចសន្យាទិញលក់ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៩ ដល់ឈ្មោះ* [redacted] *ស៊ីវហុង ចំនួន ៣០,០០០ (បីម៉ឺន) ដុល្លារអាមេរិក។*

*ខ.* *បង្គាប់សហចុងចម្លើយទទួលខុសត្រូវរួមគ្នា និង/ឬដោយឡែកពីគ្នា សំណងជំងឺចិត្ត ការខាតបង់ពេលវេលា និងសេវាកម្មច្បាប់ដល់ឈ្មោះ* [redacted] *ស៊ីវហុង ចំនួន ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក។*

*គ.* *ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។*

យល់ឃើញថា ខ្លឹមសារនៃការទាមទារដែលមាននៅក្នុងពាក្យបណ្តឹងតវ៉ាតតិយជន ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ និងពាក្យសុំកែតម្រូវពាក្យបណ្តឹង ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ របស់ដើមចោទឈ្មោះ [redacted] ស៊ីវហុង ផ្ទុយនឹងខ្លឹមសារនៃមាត្រា ៣៦៥ (បណ្តឹងតវ៉ារបស់តតិយជន) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២. តុលាការបានធ្វើការដំណើរការនីតិវិធីរហូតដល់ចប់ការទាញហេតុផលដោយផ្ទាល់មាត់ក៏ដើមចោទនៅតែមិនបានកែតម្រូវខ្លឹមសារនៃការទាមទារ ទាំងការទាមទារចម្បង និងការទាមទារបន្ទាប់បន្សំ ឱ្យស្របតាមមាត្រា ៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៣. ផ្អែកតាមសំអាងហេតុទី១ និងទី២ ខាងលើ គប្បីតុលាការច្រានចោលការទាមទារទាំងមូលដែលមាននៅក្នុងពាក្យបណ្តឹងតវ៉ាតតិយជន ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ និងពាក្យសុំកែតម្រូវពាក្យបណ្តឹង ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ របស់ដើមចោទឈ្មោះ [redacted] ស៊ីវហុង ។

<u>៤.២. ស្តីពីបន្ទុកប្រាក់ប្រដាប់ក្តី៖</u>

➢ ប្រាក់ប្រដាប់ក្តីអនុវត្តតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## **<u>សេចក្តីសម្រេចបញ្ចប់</u>**

**១** - ច្រានចោល ការទាមទារទាំងមូល ដែលមាននៅក្នុងពាក្យបណ្តឹងតវ៉ាតតិយជន ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២០ និងពាក្យសុំកែតម្រូវពាក្យបណ្តឹង ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ របស់ដើមចោទឈ្មោះ [redacted] ស៊ីវហុង ។

**២** - ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទឈ្មោះ [redacted] ស៊ីវហុង ។

- *សាលក្រមនេះ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ ជាសាធារណៈ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣។ ក្នុងករណីដែលភាគីមិនសុខចិត្តនឹងសាលក្រម អាចប្តឹងឧទ្ធរណ៍ ក្នុងអំឡុងពេល ១ ខែ ចាប់ពីថ្ងៃដែលទទួលអនុសារសាលក្រម។*

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា** [redacted]

---

" បានចម្លងត្រឹមត្រូវតាមច្បាប់ដើម "

ថ្ងៃចន្ទ ១០កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

ធ្វើនៅកំពត, ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

ទំព័រទី៥

[redacted]

**បានឃើញ**

**ចៅក្រម**

[redacted]